# មេរៀនសង្ខេប

- គ្រប់ប្រូតេអ៊ីនសុទ្ធតែជាសមាសធាតុគីមីនៃជីវិត។ប្រូតេអ៊ីនមាននាទីដ៏ធំធេងក្នុងសារពាង្គកាយរស់។វាជាម៉ាក្រូម៉ូលេគុលសាំញ៉ាំ។ប្រូតេអ៊ីនចូលរួមក្នុងតម្រូវមេតាបូលីស ដំណឹកនាំ ការការពារ និងកាតាលីករជីវៈ ។
- ប៉ូលីប៉ិបទីតជាប៉ូលីមែនៃអាស៊ីតអាមីណេ ។ ប្រូតេអ៊ីនមាន ច្រវាក់ប៉ូលីប៉ិបទីតមួយឬច្រើន ។
- គេធ្វើចំណែកថ្នាក់ប្រូតេអ៊ីនដោយផ្អែកលើទម្រង់និងសមាសធាតុរបស់វា។ទម្រង់ទី1កើតឡើងពីតំណលំដាប់អាស៊ីតអាណេសុទ្ធ ហើយជាគ្រឹះនៃព័ត៌មានសេនេទិច។ អាស៊ីតអាមីនេនីមួយៗមានអាតូមកាបូននៅកណ្ដាល ដែលភ្ជាប់ទៅនឹងបណ្ដុំអាមីន បណ្ដុំកាបុកស៊ីល និង រ៉ាឌីកាល់ R ។ នៅពេលច្រវាក់ប៉ូលីប៉ិបទីតបត់បែនជាច្រើនផ្នត់ វាបង្កើតបានទម្រង់ទី 2 រួចទី 3 ។ ឯទម្រង់ទី4 ជាប្រតេអ៊ីនដែលមានច្រវាក់ប៉ូលីប៉ិបទីតច្រើន ។ ប្រូតេអ៊ីនសរសៃជា ម៉ូលេគុលមូល វែងមិនរលាយក្នុងទឹក ហើយអាចប៉ះបាន ។ ឯប្រូតេអ៊ីនគ្រាប់ ជាម៉ូលេគុលតូចៗ រាងស៊ែ រលាយក្នុងទឹក។
- មានកត្តាជាច្រើនដែលអាចធ្វើឱ្យប្រូតេអ៊ីនបាត់បង់គុណភាពពីធម្មជាតិ ដូចជាអាស៊ីតឬបាសខ្លាំង ភ្នាក់ងារផ្សេងៗ សាប៊ូកំហាប់អំបិល លោហធាតុធ្ងន់ បម្រែបម្រួលសីតុណ្ហភាព និង ចលនាមេកានិច ។